ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៨៧ សហវ.ពន

# ប្រកាស
## ស្តីពី
## ការបែងចែកប្រាក់រង្វាន់របស់អង្គភាពពន្ធដារ

### ទេសរដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស-រកត-១១៩៨-៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញ ព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ-បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស-រកម-០២៩៧-០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧
- បានឃើញ ប្រកាសលេខ ០០៤ ប្រក-សហវ-ពដ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០១ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការផ្តល់រង្វាន់ជូនអង្គភាពពន្ធដារ
- បានឃើញ តម្រូវការនៃការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមលិខិតស្នើរបស់ប្រធាននាយកដ្ឋានពន្ធដារ ។

## សំរេច :

**ប្រការ១** : ប្រាក់រង្វាន់អង្គភាពពន្ធដារ តាមប្រកាសលេខ ០០៤ ប្រក/សហវ/៣៨ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០១ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតិឱ្យធ្វើការបែងចែកដូចតទៅសំរាប់បង្កើតបេឡាចំនួនបី :

- ២០% នៃសរុបប្រាក់រង្វាន់ប្រចាំឆ្នាំ សំរាប់បេឡាឧបត្ថម្ភបុគ្គល
- ២០% នៃសរុបប្រាក់រង្វាន់ប្រចាំឆ្នាំ សំរាប់បេឡាសមូហភាព
- ៦០% នៃសរុបប្រាក់រង្វាន់ប្រចាំឆ្នាំ សំរាប់បេឡាសំភារៈមធ្យោបាយប្រើប្រាស់ ជួសជុល សាងសង់អាគារអង្គភាពពន្ធដារ ។

**ប្រការ២** : ការប្រើប្រាស់ប្រាក់រង្វាន់នៃបេឡានីមួយៗត្រូវបានកំណត់ ដូចតទៅ :

**១-ប្រាក់រង្វាន់នៃបេឡាឧបត្ថម្ភបុគ្គល :**

ប្រាក់រង្វាន់នៃបេឡានេះ ត្រូវបានប្រើប្រាស់សំរាប់ឧបត្ថម្ភមន្ត្រីពន្ធដារក្នុងមួយត្រីមាសម្តងដោយផ្អែកតាមចំណាត់ថ្នាក់មន្ត្រី ពិន្ទុ និងតំលៃពិន្ទុ ដែលកំណត់ដោយប្រធាននាយកដ្ឋានពន្ធដារ ។

**២-បេឡាសមូហភាព :**

បេឡាសមូហភាពត្រូវបានប្រើប្រាស់សំរាប់ :

**ក-ឧបត្ថម្ភចំពោះមន្ត្រីរាជការពន្ធដារដែលមានគ្រោះថ្នាក់ឈឺថ្កាត់ឬជួបប្រទះមហន្តរាយផ្សេងៗក្នុងជីវភាពរស់នៅប្រចាំថ្ងៃ**

ក្នុងករណីមន្ត្រីរាជការពន្ធដារមានជួបប្រទះគ្រោះថ្នាក់ ឈឺថ្កាត់ មហន្តរាយផ្សេងៗ ត្រូវទទួលបានការឧបត្ថម្ភដូចខាងក្រោម :

| | | |
|---|---|---|
| - គ្រោះថ្នាក់ធ្ងន់ធ្ងរឧបត្ថម្ភជូន | ២.០០០.០០០ រៀល | (ពីរលានរៀល) |
| - ឆ្លងទន្លេ (សំរាលកូន) | ៥០០.០០០ រៀល | (ប្រាំរយពាន់រៀល) |
| - ជំងឺរាំរ៉ៃ | ១.០០០.០០០ រៀល | (មួយលានរៀល) |
| - ចូលនិវត្តន៍ | ២.០០០.០០០ រៀល | (ពីរលានរៀល) |
| - ទទួលមរណៈភាព | ២.០០០.០០០ រៀល | (ពីរលានរៀល) |

**ខ-ឧបត្ថម្ភជូនរដ្ឋអំណាចនិងអង្គភាពដែលបានជួយសហការក្នុងការប្រមូលពន្ធ :**

ការឧបត្ថម្ភប្រាក់រង្វាន់ជូនរដ្ឋអំណាច និង អង្គភាពដែលបានជួយសហការអនុវត្តច្បាប់ស្តីពីពន្ធដារទាក់ទិនដល់ប្រភេទពន្ធប្រថាប់ត្រា ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ពន្ធតែមប្រើសារពើពន្ធ និង ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវបានអនុវត្ត ដូចតទៅ :

- ចំពោះពន្ធប្រថាប់ត្រា :

ចំពោះការគ្រប់គ្រងប្រមូលពន្ធប្រថាប់ត្រាត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់ប្រាក់បេឡាសមូហភាព ដោយគណនាតាមសមាមាត្រ១% (មួយភាគរយ) លើប្រាក់ចំណូលពីពន្ធប្រថាប់ត្រា ឧបត្ថម្ភជូនរដ្ឋអំណាចដែលផ្ទះដី ដីសង់លំនៅដ្ឋានទាំងនោះតាំងនៅ ។

- ចំពោះពន្ធតែមប្រើសារពើពន្ធ :

ចំពោះការគ្រប់គ្រងប្រមូលពន្ធតែមប្រើ ត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់ប្រាក់រង្វាន់ ដោយគណនាតាមសមាមាត្រ ១%

(មួយភាគរយ) លើចំណូលបានមកពីការលក់តែមប្រើសម្រាប់ផ្តល់ជាកំរៃដល់បញ្ញរតនាគារគ្រប់ជាន់ថ្នាក់ និង បណ្តាញលក់តែមប្រើសារពើពន្ធផ្ទាល់ ។

- ចំពោះពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ :

ចំពោះការគ្រប់គ្រងប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ប្រាក់រង្វាន់ដោយគណនាតាមសមាមាត្រ ៣០% (សាមសិបភាគរយ) លើប្រាក់ពិន័យពីប្រភេទពន្ធនេះ សំរាប់ចែកជូនដល់សមាជិកនៃក្រុមប្រតិបត្តិការត្រួតពិនិត្យ និង ៥% (ប្រាំភាគរយ) សំរាប់ខុទ្ទកាល័យសាលាខេត្ត- ក្រុង ។

- ចំពោះពន្ធលើដីធ្លីមិនបានប្រើប្រាស់ :

ចំពោះការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់ប្រាក់រង្វាន់ជូនដល់អង្គភាពដែលបានជួយសហការក្នុងការអនុវត្តន៏ប្រភេទពន្ធនេះ ដោយគណនាតាមសមាមាត្រ ដូចខាងក្រោម :

១% (មួយភាគរយ) លើចំណូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ សំរាប់បែងចែកជូនដល់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

២% (ពីរភាគរយ) លើចំណូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ សំរាប់បែងចែកជូនដល់អនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

១% (មួយភាគរយ)លើចំណូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ សំរាប់បែងចែកជូនដល់អាជ្ញាធរស្រុក-ខ័ណ្ឌ

១% (មួយភាគរយ)លើចំណូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ សំរាប់បែងចែកជូនដល់អាជ្ញាធរឃុំ-សង្កាត់

រៀងរាល់ត្រីមាស ការិយាល័យនិងសាខាពន្ធដារខេត្ត-ក្រុង ត្រូវលើកសំនើស្នើសុំប្រាក់រង្វាន់មកនាយកដ្ឋានពន្ធដារទាក់ទិននិងប្រភេទពន្ធទាំងបួន តាមសមាមាត្រ និង មុខសញ្ញាដែលត្រូវទទួលបើកផ្តល់ប្រាក់រង្វាន់ ដូចមានចែងក្នុងចំណុចទី២នៃប្រការ២ខាងលើ ។ មិនអនុញ្ញាតិអោយការិយាល័យ ឬ សាខាពន្ធដារខេត្ត-ក្រុង ដកប្រាក់រង្វាន់ប្រើប្រាស់មុនរួចបានស្នើទូទាត់ជាក្រោយឡើយ ។

គ-**ឧបត្ថម្ភដល់ក្រសួងស្ថាប័នដែលជួយរដ្ឋបាលពន្ធដារក្នុងការប្រមូលពន្ធ** :

បេឡាសមូហភាពត្រូវបានអនុញ្ញាតិអោយឧបត្ថម្ភដល់ក្រសួងស្ថាប័ន ដែលបានជួយនាយកដ្ឋានពន្ធដារ ក្នុងការសហការ ឬ ផ្តល់ពត៏មានជាឯកសារផ្សេងៗទាក់ទងដល់មូលដ្ឋានកំណត់ ពន្ធ និង ការត្រួតពិនិត្យពន្ធ ។

បេឡាសមូហភាពនេះក៏ត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់សំរាប់ចំណាយអោយការអនុវត្តវិធានការតឹងទារជាក់ស្តែងដូចជាចំណាយលើការជួលមេធាវី ឬ ចំណាយទាក់ទងដល់ នីតិវិធីតុលាការ និង កំលាំងមានសមត្ថកិច្ចដែលបានជួយសហការក្នុងការអនុវត្តន៏វិធានការតឹងទារ ។

៣.**បេឡាសំភារៈមធ្យោបាយប្រើប្រាស់** :

ប្រាក់រង្វាន់ដែលនៅសល់ពីការប្រើប្រាស់សំរាប់បេឡាឧបត្ថម្ភបុគ្គល និង បេឡាសមូហភាព ត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់សំរាប់ទិញគ្រឿងសំភារៈការិយាល័យ ឧបករណ៏ប្រើប្រាស់ រៀបចំប្រព័ន្ធពត៏មានវិទ្យា យានជំនិះបំរើការងារ ជួសជុល ឬ សាងសង់អាគារ របស់អង្គភាពពន្ធដារ ។

**ប្រការ៣** : នាយកដ្ឋានពន្ធដារ ត្រូវបានអនុញ្ញាតិឱ្យមានរបបផ្តល់រង្វាន់តែមួយគត់ គឺរបបផ្តល់រង្វាន់តាមប្រកាសលេខ ០០៤ ប្រក.សហវ.ពដ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០១ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ បទប្បញ្ញត្តិទាំងឡាយដែលមាន

កន្លងមកទាក់ទងដល់ការផ្តល់រង្វាន់ ឬ ការលើកទឹកចិត្តដល់មន្ត្រីពន្ធដារ ឬ អង្គភាព ស្ថាប័ននានា ដែលបានជួយសហការជាមួយអង្គភាពពន្ធដារក្នុងការគ្រប់គ្រងប្រមូលពន្ធត្រូវចាត់ទុកជានិរាករណ៍ ។

**<u>ប្រការ៤</u>** : ត្រូវបានប្រគល់សិទ្ធិជូននាយកដ្ឋានពន្ធដារក្នុងការចំណាយបែងចែកប្រាក់រង្វាន់ទៅតាមសមាមាត្រ និង មុខសញ្ញាដែលត្រូវទទួលប្រាក់រង្វាន់ ដូចមានចែងនៅក្នុងប្រការ១ ។

**<u>ប្រការ៥</u>** : រៀងរាល់ត្រីមាស ឆមាស និងឆ្នាំ នាយកដ្ឋានពន្ធដារ ត្រូវធ្វើរបាយការណ៍បូកសរុបពីស្ថានភាពចំណូលនិងចំណាយបេឡាប្រាក់រង្វាន់ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីពិនិត្យ និង សំរេចទូទាត់ ។

**<u>ប្រការ៦</u>** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានរតនាគារជាតិ និង អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០០៣

**គាត ឈន់**

**<u>ចម្លងជូន</u>** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- "ដើម្បីជូនជ្រាប"
- ដូចប្រការ ៦
- កាលប្បវត្តិ-ឯកសារ